# កញ្ញា ឈុំ វី

*“អ្នកស្រឡាញ់ភេទដូចគ្នាត្រូវតែក្លាហាន ហ៊ានបញ្ចេញប្រាប់អ្នកដទៃ ជាពិសេសគ្រួសាររបស់ខ្លួន។ សំខាន់បំផុតនោះ យើងមិនត្រូវធ្វើអំពើលួចប្លន់ ឬសេពគ្រឿងញៀននោះទេ យើងត្រូវធ្វើអំពើល្អៗ និងធ្វើការងារណាដែលសង្គមទទួលស្គាល់។”*



កញ្ញា ឈុំ វី មានអាយុ ៣១ ឆ្នាំជាសកម្មជនអ្នកស្រឡាញ់ភេទដូចគ្នា រស់នៅភូមិស្ពោ ឃុំបាយ ស្រុកបាភ្នំ ខេត្តព្រៃវែង។ កញ្ញាបានក្លាយជាសកម្មជនអ្នកស្រឡាញ់ភេទដូចគ្នាតាំងពីឆ្នាំ២០១៤ មកដល់បច្ចុប្បន្ន។

កញ្ញាបានចូលរួមសកម្មភាពជាច្រើនដូចជា ការប្រជុំ សិក្ខាសាលា ការធ្វើបទបង្ហាញ ការជួយណែនាំអ្នកស្រឡាញ់ភេទដូចគ្នា ការសម្តែងរឿងអប់រំអំពីអ្នកស្រឡាញ់ភេទដូចគ្នានៅតាមផ្ទះអ្នកស្រឡាញ់ភេទដូចគ្នាជាដើម។ល។ ដើម្បីទាមទារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាឱ្យមានសិទ្ធិដូចមនុស្សទូទៅដែរ ដូចជាសិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ និងសិទ្ធិចិញ្ចឹមកូនជាដើម។ កញ្ញាកត់សម្គាល់ថាមានភាពជោគជ័យមួយចំនួនក្នុងការលើកកម្ពស់សិទ្ធិសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ដូចជាកាត់បន្ថយការរើសអើងអ្នកស្រឡាញ់ភេទដូចគ្នា ជួយអ្នកស្រឡាញ់ភេទដូចគ្នាឱ្យមានជំនាញ និងការងារប្រសើរជាងមុន និងផ្សព្វផ្សាយឱ្យមនុស្សមួយចំនួន រួមទាំងសមាជិកគ្រួសាររបស់អ្នកស្រឡាញ់ភេទដូចគ្នាបានយល់ដឹងអំពីសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា។

កញ្ញាធ្លាប់បានទទួលការរើសអើងពីសំណាក់អាជ្ញាធរ និងមនុស្សទូទៅ ដោយការប្រើប្រាស់ពាក្យសម្តីមិនសមរម្យ ការគំរាមកំហែង ហើយមានពេលខ្លះត្រូវបានគេប្រើអំពើហិង្សាមកលើកញ្ញាទៀតផង ដោយសារកញ្ញាគឺជាអ្នកប្តូរយេនឌ័រជាស្ត្រីនិងជាសកម្មជនការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា។ ប៉ុន្តែ កញ្ញាជឿជាក់ថាការងារនេះ គឺមានសារៈសំខាន់ណាស់ពីព្រោះវានឹងជួយលើកស្ទួយអ្នកស្រឡាញ់ភេទដូចគ្នាដែលទន់ខ្សោយជួយអ្នកដែលលាក់មុខឱ្យពួកគាត់ក្លាហាន ទោះបីជាបច្ចុប្បន្នការងារលើកស្ទួយអ្នកស្រឡាញ់ភេទដូចគ្នានៅមិនទាន់ទទួលបានជាលទ្ធផលធំដុំក៏ដោយ ក៏កញ្ញានៅតែបន្តធ្វើការងារដោយក្តីពេញចិត្តរីករាយ។

កញ្ញាយល់ថាសមភាពយេនឌ័រគឺជាភាពស្មើគ្នារវាងមនុស្សទូទៅ មិនថាមនុស្សប្រុសពិត ស្រីពិត និងអ្នកស្រឡាញ់ភេទដូចគ្នានោះទេ។ បន្ថែមពីលើនេះទៀត កញ្ញាមានទស្សនៈយ៉ាងមុតមាំថា សមភាពយេនឌ័រត្រូវតែបន្តលើកតម្កើង ពីព្រោះអ្នកស្រឡាញ់ភេទដូចគ្នាមិនទាន់ដឹងច្បាស់ថាខ្លួនមានសិទ្ធិស្មើគ្នាហើយឬនៅព្រោះការរើសអើងនៅតែបន្តនៅឡើយ ហើយវាពិតជាបានបំបាក់ទឹកចិត្ត និងប៉ះពាល់ផ្លូវអារម្មណ៍របស់អ្នកស្រឡាញ់ភេទដូចគ្នាខ្លាំងណាស់៕

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

CC BY NC SA

ខែធ្នូ ឆ្នាំ២០១៩